អេស៊ីលីដា ACLEDA BANK

# លក្ខខណ្ឌទូទៅក្នុងការប្រតិបត្តិគណនីជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី

លក្ខខណ្ឌទូទៅ ឬហៅថា "កិច្ចព្រមព្រៀង" នេះ ត្រូវបានបង្កើតឡើងជាបទដ្ឋានក្នុងការប្រតិបត្តិគណនីធនាគារប្រកបដោយតម្លាភាព និងការគាំពារអតិថិជន ដោយលក្ខខណ្ឌទូទៅនេះនឹងប្រើប្រាស់សម្រាប់អមជាមួយ "លក្ខខណ្ឌ និងថ្លៃសេវានៃប្រតិបត្តិការគណនី (Conditions and Fees Charge of Account Operation)" និង "តារាងអត្រាការប្រាក់ (Interest Rate Table)" ជូនអតិថិជន។ លក្ខខណ្ឌគណនី ឬកិច្ចព្រមព្រៀងនេះ រួមនឹងលក្ខខណ្ឌ និងថ្លៃសេវានៃប្រតិបត្តិការគណនី បានពន្យល់អំពីការដាក់ប្រាក់ សន្សំ និងសេវាផ្សេងៗទៀតដែលធនាគារ អេស៊ីលីដា ភីអិលស៊ី ផ្តល់សេវាកម្មជូនអតិថិជន។

នៅពេលអតិថិជនយល់ព្រមបើកគណនីនៅចំពោះមុខភ្នាក់ងារ ឬបើកគណនីដោយខ្លួនឯងតាមម៉ាស៊ីនស្វ័យប្រវត្តិ ឬប្រព័ន្ធអនឡាញ បញ្ជាក់ថាអតិថិជនត្រូវបានពន្យល់ និងណែនាំ ឬអានដោយខ្លួនឯង បានយល់ច្បាស់គ្រប់លក្ខខណ្ឌទាំងអស់នៃកិច្ចព្រមព្រៀងនេះ និងព្រមព្រៀងចំពោះថ្លៃសេវានៃប្រតិបត្តិការគណនី និងអត្រាការប្រាក់ ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ហើយកិច្ចព្រមព្រៀងនេះនឹងត្រូវបានចូលជាធរមាន។

ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចធ្វើការកែប្រែលើកិច្ចព្រមព្រៀង អត្រាការប្រាក់ លក្ខខណ្ឌ និងថ្លៃសេវានៃប្រតិបត្តិការគណនី នៅពេលណាមួយ ដោយអនុលោមទៅតាមច្បាប់ជាធរមាន និង/ឬស្ថានភាពជាក់ស្តែង។ កំណែទម្រង់ចុងក្រោយនឹងមានរក្សាទុកនៅក្នុងគេហទំព័រ https://www.acledabank.com.kh ដើម្បីផ្សព្វផ្សាយជូនអតិថិជនទូទៅ និងអនុវត្តក្នុងការប្រើប្រាស់គណនីជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងជូនដំណឹងទៅអតិថិជននូវរាល់ការកែប្រែទាំងឡាយណាដែលប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន (តាមលទ្ធភាពដែលធនាគារអាចធ្វើទៅបាន)។

ពាក្យថា "អតិថិជន" គឺសំដៅដល់អ្នកសុំបើកគណនី ឬម្ចាស់គណនី ឬអ្នកប្រើប្រាស់សេវាកម្មរបស់ធនាគារ។

ពាក្យថា "ធនាគារ" គឺសំដៅដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

## ១ ម្ចាស់គណនី

អតិថិជន អាចបើកគណនីក្នុងនាមខ្លួនឯងផ្ទាល់ ឬមានអ្នករួមជាមួយម្នាក់ ឬច្រើននាក់ផ្សេងទៀត ក្នុងនាមជាអ្នករួមគណនី ឬក្នុងនាមជាក្រុមហ៊ុន។ ខាងក្រោមនេះ គឺជាប្រភេទនៃម្ចាស់គណនី ៖

### ១.១ ឯកត្តជន

គណនីនេះបើកដោយឯកត្តជនដែលមានឈ្មោះតែម្នាក់ឯង ជាម្ចាស់ ឬអ្នកទទួលផល "អត្ថគាហក" តែម្នាក់គត់នៃគណនី។

### ១.២ ក្រុមហ៊ុន

គណនីនេះបើកដោយបុគ្គលដែលបានផ្តល់សិទ្ធិឲ្យបើកគណនី ក្នុងនាមជាក្រុមហ៊ុន។ ក្នុងនោះរួមមាន ៖ សហកម្មសិទ្ធិ សាជីវកម្ម អង្គការ/សមាគម/សហគមន៍ ស្ថានទូត ក្រសួង/មន្ទីរ/ស្ថាប័ន និងគម្រោងអភិវឌ្ឍន៍នានា។ល។

### ១.៣ គណនីរួម

នៅពេលដែលអតិថិជនមានភាគីពីរ ឬច្រើន "អតិថិជនរួម" លក្ខខណ្ឌទាំងនេះ នឹងត្រូវអនុវត្តចំពោះអតិថិជនរួមផង និងជាបុគ្គលផង។ "អតិថិជនរួម" ម្នាក់ៗ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះធនាគារ លើបំណុលទាំងមូលនៃគណនីរួមដែលជំពាក់ធនាគារ។

## ២ ការបើកគណនី

**២.១** អតិថិជនត្រូវបំពេញ និងផ្តិតស្នាមមេដៃ/Biometric ឬចុះហត្ថលេខាលើពាក្យសុំបើកគណនី ដែលបានផ្តល់ជូនដោយធនាគារ និងផ្តល់នូវឯកសារសម្គាល់អត្តសញ្ញាណឯកត្តជន ឬក្រុមហ៊ុន/ស្ថាប័ន និងឯកសារផ្សេងៗ ទៅតាមគោលការណ៍ និងនីតិវិធីរបស់ធនាគារ ដើម្បីបញ្ជាក់នូវភាពត្រឹមត្រូវ ពិតប្រាកដ និងយកជាការបាន។ ប្រសិនបើមានការផ្លាស់ប្តូរព័ត៌មានអ្វីមួយនៅក្នុងពាក្យស្នើសុំ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារ។ ក្នុងករណីអតិថិជនគ្មានលទ្ធភាពចុះហត្ថលេខា ឬផ្តល់ស្នាមម្រាមដៃ ដោយពិការភាពត្រូវអនុវត្តដូចខាងក្រោម ៖

- អតិថិជនពិការភ្នែកទាំងសងខាង : តម្រូវឲ្យមានបុគ្គលម្នាក់ទៀតជានីតិជនមកអមជាមួយ (អាណាព្យាបាល ឬសាច់ញាតិ ឬបុគ្គលណាម្នាក់ដែលអតិថិជនជឿទុកចិត្ត...) ហើយមានសរសេរបញ្ជាក់អះអាងនៅលើឯកសារសម្គាល់អត្តសញ្ញាណដែលបានថតចម្លងចេញពីច្បាប់ដើម របស់បុគ្គលនោះ នូវសម្ថ័ន្ធភាព និងការទទួលខុសត្រូវក្នុងនាមជាសាក្សី។
- អតិថិជនពិការដៃទាំងសងខាង : អតិថិជនត្រូវផ្តិតមេជើងជំនួសមេដៃ ឬត្រូវអនុវត្តដូចអតិថិជនពិការភ្នែក។

**២.២** នៅពេលបើកគណនី អតិថិជនត្រូវដាក់ប្រាក់តម្កល់ក្នុងគណនីនោះនូវចំនួនទឹកប្រាក់ដែលមិនទាបជាងចំនួនទឹកប្រាក់អប្បបរមា ដែលបានកំណត់ដោយធនាគារ។

**២.៣** គណនីចរន្ត តម្រូវឲ្យអតិថិជនប្រើប្រាស់មូលប្បទានបត្រ ដើម្បីធ្វើប្រតិបត្តិការ។ ចំណែកឯគណនីបញ្ញើសំចៃ អាចប្រើប្រាស់សៀវភៅប្រាក់បញ្ញើ ឬប័ណ្ណព័ត៌មានគណនី អាស្រ័យទៅតាមតម្រូវការរបស់អតិថិជន។

**២.៤** ចំពោះគណនីចរន្តគ្រប់ប្រភេទ អតិថិជនយល់ព្រមអនុញ្ញាតផ្តល់សិទ្ធិឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី នូវរាល់ការបញ្ចូលព័ត៌មានការចេញមូលប្បទានបត្រដែលសំវិធានធនមិនគ្រប់គ្រាន់ ឬគ្មាន ទៅឲ្យតតិយជន តាមរយៈក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ សម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន។ ទន្ទឹមនឹងនេះ អតិថិជនមានសិទ្ធិទទួលព័ត៌មាន និងទិន្នន័យរបស់ខ្លួន និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ស្របតាមនីតិវិធី ដូចមានចែងក្នុងប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទានរបស់ធនាគារជាតិនៃកម្ពុជា។

២.៥ គ្រប់គណនីទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យភ្ជាប់សេវាអេស៊ីលីដាម៉ូបាល និង/ឬសេវាអេស៊ីលីដាអ៊ីនធើណែត ដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រង និងធ្វើប្រតិបត្តិការគណនីដូចជា ការផ្ទេរប្រាក់ ការទូទាត់ប្រាក់ ការផ្ទេរប្រាក់ចេញ-ចូលគណនីជួញដូរមូលបត្រ និងជាពិសេសការពិនិត្យមើលរបាយការណ៍គណនី បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ល។ ចំពោះគណនីរបស់អតិថិជនដែលទទួលអត្ថប្រយោជន៍ពី ប.ជ.ស ឬ ប.ជ.អ ឬ ម.ជ.ព អាចមានការលើកលែង ប្រសិនបើអតិថិជនមិនអាចប្រើបាន។

២.៦ អតិថិជនជាម្ចាស់គណនីដែលមានសញ្ជាតិអាមេរិក (US Citizen) តម្រូវឲ្យផ្តល់នូវលេខសម្គាល់អត្តសញ្ញាណពន្ធ (TIN-Tax identification number) តាមរយៈការបំពេញទម្រង់ W-9 ស្របតាមអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់បុគ្គលអាមេរិកដូចមានចែងនៅក្នុងគោលការណ៍របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធរមាន។

## ៣ ការបិទគណនី

៣.១ ការបិទគណនីឯកត្តជន ម្ចាស់គណនីត្រូវបំពេញពាក្យសុំបិទគណនីដែលផ្តល់ជូនដោយធនាគារ ចំណែកគណនីរួម ត្រូវមានការព្រមព្រៀងពីគ្រប់សមាជិកទាំងអស់ ឬអាចអនុញ្ញាតឲ្យសមាជិកណាម្នាក់ទៅតាមលក្ខខណ្ឌប្រតិបត្តិការស្នើសុំបិទគណនី ទៅតាមការកំណត់របស់ធនាគារ។ ចំពោះសមតុល្យទឹកប្រាក់នៅសល់ក្នុងគណនី ត្រូវអនុវត្តតាមលក្ខខណ្ឌនៃប្រតិបត្តិការ និងគំរូហត្ថលេខាដែលមានតម្កល់នៅធនាគារ។

៣.២ ការបិទគណនីក្រុមហ៊ុន/ស្ថាប័ន អតិថិជន (ម្ចាស់គណនី ឬអ្នកមានសិទ្ធិ) ត្រូវធ្វើលិខិតស្នើសុំបិទគណនីដោយមានចុះហត្ថលេខា និងបោះត្រា (ប្រសិនបើមាន) ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ឬបំពេញពាក្យសុំបិទគណនី ហើយចំពោះការដកសមតុល្យទឹកប្រាក់នៅសល់ក្នុងគណនី ត្រូវអនុវត្តតាមលក្ខខណ្ឌនៃប្រតិបត្តិការ និងគំរូហត្ថលេខា ដែលមានតម្កល់នៅធនាគារ។

៣.៣ ការបិទគណនីក្នុងរយៈពេល ០៣ខែ (បីខែ) គិតចាប់ពីថ្ងៃបើកគណនីអាចធ្វើទៅបាន ប៉ុន្តែអតិថិជនត្រូវបង់ថ្លៃសេវាតាមការកំណត់របស់ធនាគារ។

៣.៤ ការបិទគណនីបញ្ញើសំចៃ មិនតម្រូវឲ្យអតិថិជនប្រគល់សៀវភៅប្រាក់បញ្ញើ និងប័ណ្ណព័ត៌មានគណនីមកវិញទេ លើកលែងតែករណីចាំបាច់ប៉ុណ្ណោះ។

៣.៥ ការបិទគណនីចរន្ត អតិថិជនត្រូវប្រគល់មូលប្បទានបត្រដែលនៅសល់ទាំងអស់ជូនធនាគារវិញ និងត្រូវប្រាកដថា គ្មានមូលប្បទានបត្រណាមួយដែលចេញប្រើប្រាស់រួចហើយ ដោយមិនទាន់បានទូទាត់នោះទេ បើមិនដូច្នោះទេ អតិថិជនត្រូវធ្វើការធានាជាលាយលក្ខណ៍អក្សរ មុននឹងបិទគណនីនោះ។ ក្នុងករណីម្ចាស់គណនីចេញមូលប្បទានបត្រដែលមានសំវិធានធនមិនគ្រប់គ្រាន់ ឬគ្មាន លើសពីបីដងឡើងទៅ ធនាគាររក្សាសិទ្ធិក្នុងការបិទគណនីអតិថិជនដោយស្វ័យប្រវត្តិ ទោះបីជាធនាគារមិនទាន់បានប្រមូលមូលប្បទានបត្រដែលនៅសល់ ឬមិនទាន់ទូទាត់ក៏ដោយ។

៣.៦ ប្រសិនបើធនាគារតម្រូវឲ្យមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ទើបអាចបើកគណនី រក្សាគណនី និងធ្វើប្រតិបត្តិការគណនីជាមួយធនាគារបាន អតិថិជនត្រូវធ្វើតាមការស្នើសុំនោះ។ ធនាគារអាចស្នើឲ្យអតិថិជនផ្តល់នូវឯកសារនៃការយល់ព្រមទាំងនេះ នៅពេលណាក៏បាន។

៣.៧ ធនាគាររក្សាសិទ្ធិក្នុងការបង្កក/ឃាត់ទុក/រឹបអូសជាបណ្តោះអាសន្ន (ដោយមានការណែនាំ ឬស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ច) ឬបិទគណនីដោយមិនចាំបាច់ជូនដំណឹងអតិថិជនទេ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ៖

- អតិថិជនមិនបានអនុវត្តទៅតាមគោលការណ៍ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងការប្រតិបត្តិគណនី ដូចជា ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ល។
- ប្រតិបត្តិការគណនីរបស់អតិថិជនផ្ទុយនឹងច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសដទៃទៀត ឬជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គល ឬអង្គភាពដែលត្រូវបានហាមឃាត់ ឬជាប្រយោជន៍បម្រើដល់សកម្មភាពល្មើសច្បាប់ ឬផ្ទេរប្រាក់ទៅ-មកពីបណ្តាប្រទេសដែលស្ថិតក្នុងទណ្ឌកម្មសេដ្ឋកិច្ច។ល។

## ៤ ប្រតិបត្តិការគណនី

៤.១ រាល់ការបង្គាប់មកធនាគារ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវផ្តិតស្នាមមេដៃ/Biometric ឬមានចុះហត្ថលេខាដោយផ្ទាល់ (សំណៅដើម) ពីអតិថិជន (ម្ចាស់គណនី ឬអ្នកដែលមានសិទ្ធិ) ដែលដូចគ្នាទៅនឹងស្នាមមេដៃ/Biometric ឬហត្ថលេខា ដែលបានតម្កល់នៅធនាគារ ក្នុងករណីអតិថិជនគ្មានលទ្ធភាពចុះហត្ថលេខា ឬផ្តល់ស្នាមម្រាមដៃ ដោយពិការភាពត្រូវអនុវត្តដូចលក្ខខណ្ឌបើកគណនី។ ការដកប្រាក់ ឬផ្ទេរប្រាក់ តាមរយៈម៉ាស៊ីនថតស្នាមមេដៃស្វ័យប្រវត្តិ ក្រោមចំនួនកំណត់ គឺមិនមានការចុះហត្ថលេខា ឬផ្តិតមេដៃលើទម្រង់ដកប្រាក់ ឬផ្ទេរប្រាក់នោះទៀតឡើយ។ ធនាគារមិនទទួលយកនូវលិខិតបង្គាប់ថតចម្លង ឬការបង្គាប់តាមទូរសព្ទ ទូរសារ ឬតាមសារអេឡិចត្រូនិកឡើយ លុះត្រាតែមានការព្រមព្រៀងជាពិសេសណាមួយជាលាយលក្ខណ៍អក្សរពីធនាគារ។ រាល់លិខិតបង្គាប់ ឬឯកសារ ដែលទទួលពីអតិថិជនដែលមិនមានភាពច្បាស់លាស់ ឬមានទំនាស់នឹងគ្នា ធនាគារមិនអាចទទួលយកឯកសារនោះទេ លុះត្រាតែធនាគារបានទទួលការបញ្ជាក់ថា ឯកសារទាំងនោះពិតជាត្រឹមត្រូវ។

៤.២ អតិថិជននឹងត្រូវភ្ជាប់កាតព្វកិច្ច ដោយកិច្ចព្រមព្រៀងណាមួយដែលបានយល់ព្រមជាមួយធនាគារ ទាក់ទងទៅនឹងការចេញឲ្យប្រើប្រាស់មូលប្បទានបត្រ ឬការសរសេរមូលប្បទានបត្រ ឬការប្រតិបត្តិគណនី ក្នុងនោះរួមមាន ៖ កិច្ចព្រមព្រៀងលើការចុះហត្ថលេខារួមគ្នា ការចុះហត្ថលេខាច្រើនគ្នា សមតុល្យអតិបរមា ឬអប្បបរមានៃគណនីនីមួយៗ។

៤.៣ រាល់ប្រតិបត្តិការគណនី ដូចជា ផ្ទេរប្រាក់ចូល ដាក់ប្រាក់ ឬប្រតិបត្តិការផ្សេងៗទៀត ដែលមានប្រភេទរូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណដើមនៃគណនីដែលអតិថិជនមាននៅធនាគារ ប្រភេទរូបិយប័ណ្ណនៃប្រតិបត្តិការនោះនឹងត្រូវប្តូរទៅតាមរូបិយប័ណ្ណនៃគណនីដែលអតិថិជនកំពុងប្រតិបត្តិការដោយផ្អែកលើអត្រាប្តូរប្រាក់ផ្លូវការជាក់ស្តែងរបស់ធនាគារនៅថ្ងៃធ្វើប្រតិបត្តិការ។

៤.៤ គ្រប់ប្រភេទគណនីទាំងអស់ជារូបិយប័ណ្ណបរទេស ធនាគារមានសិទ្ធិជាឯកច្ឆន្ទ ក្នុងការបើកសាច់ប្រាក់ជូនម្ចាស់គណនីនូវចំនួនទឹកប្រាក់ណាមួយ ដែលបានដកពីគណនីរូបិយប័ណ្ណបរទេស (រូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក) តាមវិធីណាមួយ ឬវិធីទាំងពីរដូចខាងក្រោម ៖

- បើកសាច់ប្រាក់ជារូបិយប័ណ្ណដុល្លារអាមេរិក ឬរូបិយវត្ថុរៀល ដែលប្តូរពីរូបិយប័ណ្ណបរទេសក្នុងគណនី តាមអត្រាប្តូររូបិយប័ណ្ណរបស់ធនាគារនៅពេលធ្វើប្រតិបត្តិការ និង/ឬ
- បើកសាច់ប្រាក់ជារូបិយប័ណ្ណបរទេស ដូចគ្នានឹងរូបិយប័ណ្ណបរទេសក្នុងគណនី។ ករណីនេះ ធនាគារអាចគិតកម្រៃជើងសារនៃអត្រាប្តូរប្រាក់លើចំនួនទឹកប្រាក់នោះ។

**៤.៥** ចំពោះប្រតិបត្តិការជួញដូរមូលបត្រ ម្ចាស់គណនីត្រូវដាក់តម្កល់សាច់ប្រាក់យ៉ាងតិច ១០០% នៃតម្លៃមូលបត្រដែលត្រូវបានដាក់បញ្ជាទិញ បូកនឹងថ្លៃសេវានៅក្នុងគណនីជួញដូរ សម្រាប់ការបញ្ជាទិញមូលបត្រ (Trading Account Balance ≥ 100% of Total Securities Value " Securities Price* Number of Shares Purchased " Plus Trading Fee)។ ការទូទាត់សាច់ប្រាក់លើការជួញដូរមូលបត្រ រវាងគណនីសាច់ប្រាក់អតិថិជន គណនីផ្ទាល់ខ្លួន និងគណនីទូទាត់សាច់ប្រាក់របស់ក្រុមហ៊ុនមូលបត្រ និងគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រនៃផ្សារមូលបត្រកម្ពុជា ត្រូវបានធ្វើឡើងបន្ទាប់ពីធនាគារ អេស៊ីលីដា ភីអិលស៊ី បានទទួលព័ត៌មានអេឡិចត្រូនិកបង្គាប់ឲ្យទូទាត់ ដែលបញ្ជាទូទាត់ដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនមូលបត្រតាមរយៈប្រព័ន្ធរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយមិនចាំបាច់មានការបង្គាប់ ដោយផ្ទាល់ពីម្ចាស់គណនីឡើយ លើកលែងតែប្រតិបត្តិការផ្សេងពីនេះដែលត្រូវអនុវត្តជាធម្មតាទៅតាមលក្ខខណ្ឌប្រតិបត្តិការ។

## ៥ ការកែប្រែព័ត៌មានគណនី

**៥.១** គណនីគ្រប់ប្រភេទ (គណនីបញ្ញើសំចៃ គណនីចរន្ត គណនីបញ្ញើតាមតម្រូវការ ប្រាក់បញ្ញើមានកាលកំណត់ និងគណនីផ្សេងៗទៀត) អាចធ្វើការកែប្រែព័ត៌មានបានតាមតម្រូវការរបស់អតិថិជន តាមរយៈការមកបំពេញពាក្យស្នើសុំផ្លាស់ប្តូរព័ត៌មាននៅតាមការិយាល័យ ឬទាញយក (Download) តាមរយៈគេហទំព័រ: https://www.acledabank.com.kh/kh/eng/formcenter រួចបំពេញឲ្យបានត្រឹមត្រូវ ដើម្បីផ្តល់ជូនធនាគារ រួមទាំងឯកសារគតិយុត្តដែលនៅមានសុពលភាព និង/ឬឯកសារចាំបាច់ផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹងការផ្លាស់ប្តូរព័ត៌មានទាំងនេះ។ ព័ត៌មានដែលបានផ្លាស់ប្តូរនេះ មានសុពលភាពរហូតដល់មានការជូនដំណឹងជាថ្មីពីអតិថិជន ហើយអតិថិជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ដែលអាចកើតមានឡើងបណ្តាលមកពីការកែប្រែព័ត៌មានទាំងនេះ។

**៥.២** ការបំពេញពាក្យស្នើសុំផ្លាស់ប្តូរព័ត៌មានដូចខាងលើ ក៏ត្រូវបានអនុវត្តចំពោះគណនីរួម និងគណនីក្រុមហ៊ុនផងដែរ ប៉ុន្តែត្រូវមាន ការព្រមព្រៀងពីគ្រប់សមាជិកទាំងអស់ ឬអាចអនុញ្ញាតឲ្យសមាជិកណាម្នាក់ទៅតាមលក្ខខណ្ឌប្រតិបត្តិការស្នើសុំកែប្រែព័ត៌មានទាំងនេះ ទៅតាមការកំណត់របស់ធនាគារ។ ចំពោះគណនីក្រុមហ៊ុន ក៏អនុញ្ញាតឲ្យស្នើសុំកែប្រែព័ត៌មាន តាមរយៈលិខិតស្នើសុំជាលាយលក្ខណ៍អក្សរពីអតិថិជន (ម្ចាស់គណនី ឬអ្នកដែលមានសិទ្ធិ) ផងដែរ។

**៥.៣** ការផ្លាស់ប្តូរឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារពាក់ព័ន្ធនានា នៅពេលដែលឯកសារនោះជិតដល់កាលបរិច្ឆេទផុតកំណត់ ជាកាតព្វកិច្ចរបស់អតិថិជនផ្ទាល់ ដើម្បីរក្សាសុពលភាពឯកសាររបស់ខ្លួនតាមផ្លូវច្បាប់ ហើយអាចផ្តល់មកធនាគារនៅតាមការិយាល័យ ឬតាមរយៈម៉ាស៊ីនវីធីអឹម (VTM)។ ធនាគារនឹងជូនដំណឹងតាមគ្រប់មធ្យោបាយ ឬចាត់វិធានការផ្សេងៗ ដើម្បីធ្វើបច្ចុប្បន្នភាពលើឯកសារគតិយុត្ត ដែលពាក់ព័ន្ធនឹងគណនីករណីផុតសុពលភាព។

**៥.៤** ធនាគាររក្សាសិទ្ធិក្នុងការបដិសេធលើការកែប្រែព័ត៌មានអតិថិជន ប្រសិនបើត្រួតពិនិត្យឃើញថាការស្នើសុំរបស់អតិថិជន មិនត្រឹមត្រូវតាមលក្ខខណ្ឌទូទៅក្នុងការប្រតិបត្តិគណនី ជាមួយធនាគារ។

## ៦ បំណុលវិបារូបរ៍ ឬសមតុល្យឥណពន្ធ

ក្នុងករណីមានប្រតិបត្តិការដកប្រាក់លើសសមតុល្យ (សាច់ប្រាក់ដែលមាននៅក្នុងគណនី) អតិថិជនត្រូវសងប្រាក់ដែលដកលើសមកធនាគារវិញ និងត្រូវបង់ការប្រាក់លើសមតុល្យឥណពន្ធប្រចាំថ្ងៃ និងប្រាក់ពិន័យផ្សេងៗ តាមការកំណត់របស់ធនាគារ។

## ៧ ការប្រុងប្រយ័ត្ន

**៧.១** នៅពេលបាត់សៀវភៅប្រាក់បញ្ញើ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកធនាគារ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់ពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដែលបានបាត់។

**៧.២** អតិថិជនត្រូវបានផ្តល់ជូនសៀវភៅប្រាក់បញ្ញើថ្មី ជំនួសសៀវភៅប្រាក់បញ្ញើដែលបានបាត់ (សម្រាប់ប្រើប្រាស់ជាមួយគណនីចាស់ដដែល) តែត្រូវបង់ថ្លៃសេវាទៅតាមការកំណត់របស់ធនាគារ។ ធនាគារមិនទទួលខុសត្រូវចំពោះម្ចាស់គណនី ឬភាគីទីបីណាមួយ ក្នុងការប្រតិបត្តិគណនីដែលទាក់ទងទៅនឹងគណនីនោះ មុនពេលជូនដំណឹងឡើយ។

**៧.៣** នៅពេលបាត់មូលប្បទានបត្រថ្មីដែលពុំទាន់មានចុះចំនួនទឹកប្រាក់ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកធនាគារ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់នូវឈ្មោះគណនី លេខគណនី ពេលវេលា កាលបរិច្ឆេទ ទីកន្លែង ចំនួនសន្លឹក និងលេខរៀងរបស់មូលប្បទានបត្រ ដែលបាត់ ដើម្បីឲ្យធនាគារបញ្ឈប់មូលប្បទានបត្រនោះ នៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**៧.៤** នៅពេលបាត់សន្លឹកមូលប្បទានបត្រដែលមានចុះចំនួនទឹកប្រាក់ ឬបញ្ឈប់មូលប្បទានបត្រណាមួយនោះ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាបន្ទាន់ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់នូវឈ្មោះគណនី លេខគណនី ពេលវេលា កាលបរិច្ឆេទ ទីកន្លែង លេខរៀង ចំនួនទឹកប្រាក់ដែលមាននៅក្នុងមូលប្បទានបត្រ បុគ្គល/ស្ថាប័នដែលត្រូវទទួល និងមូលហេតុនៃការបញ្ឈប់មូលប្បទានបត្រនោះ។ ប្រសិនបើព័ត៌មានដែលបានផ្តល់មកមិនត្រឹមត្រូវ ធនាគារមិនទទួលខុសត្រូវចំពោះការមិនបញ្ឈប់មូលប្បទានបត្រនោះឡើយ។

**៧.៥** អតិថិជនត្រូវរក្សាសមតុល្យអប្បបរមានៅក្នុងគណនីរបស់ខ្លួនទៅតាមការកំណត់របស់ធនាគារ។ ថ្លៃសេវានឹងត្រូវកាត់ចេញពីគណនីអតិថិជនរៀងរាល់ចុងខែ នៅពេលណាដែលសមតុល្យគណនីធ្លាក់ចុះក្រោមសមតុល្យអប្បបរមា បើមិនដូច្នោះទេលុះត្រាតែមានការយល់ព្រមពីធនាគារ។

**៧.៦** នៅពេលដែលមានសមាជិក “អតិថិជនរួម” បាត់បង់សមាជិកភាព ធនាគារនឹងចាត់ចែងសមតុល្យគណនី និងសម្ភារធានាទាំងអស់ ដែលជាកម្មសិទ្ធិរបស់ “អតិថិជនរួម” តាមការបង្គាប់របស់អ្នកដែលនៅមានសមាជិកភាព តាមឯកសារយោង។

**៧.៧** នៅពេលបើកគណនី អតិថិជនអាចធ្វើការណែនាំជាមុននៅក្នុងទម្រង់បើកគណនីនូវការប្រគល់សិទ្ធិទៅឲ្យអ្នកទទួលផល អាចធ្វើប្រតិបត្តិការដកប្រាក់ និងប្រតិបត្តិការផ្សេងទៀត សម្រាប់កាលៈទេសៈអាសន្នណាមួយដែលបានកើតឡើងជាយថាហេតុ ដោយអនុវត្តតាមនីតិវិធីរបស់ធនាគារជាធរមាន។

## ៨ គណនីមូលប្បទានបត្រ ឬគណនីចរន្ត

**៨.១** មូលប្បទានបត្រត្រូវតែប្រើប្រាស់ដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយអតិថិជនត្រូវទទួលស្គាល់ថា ច្បាប់នេះអាចដាក់ការហាមឃាត់ទៅលើសកម្មភាពទូទាត់ជាក់លាក់ណាមួយ ជាប្រាក់ដុល្លារអាមេរិក ឬរូបិយប័ណ្ណបរទេសផ្សេងៗ នៅប្រទេសកម្ពុជា។ ធនាគារមិនមានកាតព្វកិច្ចក្នុងការធានាថា ប្រតិបត្តិការណាមួយស្របច្បាប់ ឬមិនស្របច្បាប់ឡើយ ប៉ុន្តែធនាគារមានសិទ្ធិបដិសេធមិនធ្វើការទូទាត់ចំពោះ ប្រតិបត្តិការណាមួយបាន រហូតដល់មានការបញ្ជាក់ថាការទូទាត់នោះមានលក្ខណៈត្រឹមត្រូវ និងស្របតាមផ្លូវច្បាប់។

៨.២ មូលប្បទានបត្រដែលបានចេញផ្សាយ ត្រូវមានសំវិធានធនគ្រប់គ្រាន់សម្រាប់ឲ្យធនាគារធ្វើការទូទាត់ បើមិនដូច្នោះទេ អតិថិជននឹងត្រូវរងការផាកពិន័យជាសាច់ប្រាក់ ស្របទៅតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង/ឬទទួលខុសត្រូវចំពោះ មុខច្បាប់។

៨.៣ មូលប្បទានបត្រត្រូវបានទូទាត់នៅពេលបង្ហាញ ទោះបីជាកាលបរិច្ឆេទនៃការបង្ហាញកើតឡើងមុនកាលបរិច្ឆេទចេញផ្សាយ ដែលបញ្ជាក់លើមូលប្បទានបត្រក៏ដោយ។ ដូច្នេះអតិថិជនត្រូវប្រាកដថា សមតុល្យទឹកប្រាក់នៅក្នុងគណនីមានគ្រប់គ្រាន់សម្រាប់ទូទាត់រាល់មូលប្បទានបត្រដែលបានចេញផ្សាយ ប្រសិនបើពុំដូច្នោះទេ ធនាគារមិនទទួលខុសត្រូវជំនួសអតិថិជនចំពោះករណីនេះឡើយ។

៨.៤ មូលប្បទានបត្រដែលប្រើដើម្បីដកប្រាក់ពីគណនីអតិថិជន ត្រូវតែជាមូលប្បទានបត្រដែលបោះពុម្ព និងចេញឲ្យប្រើប្រាស់ដោយធនាគារ ហើយបានបំពេញតាមលក្ខខណ្ឌរបស់ធនាគារ។ មូលប្បទានបត្រនីមួយៗ ត្រូវតែចុះហត្ថលេខា/ស្នាមមេដៃ ដោយអ្នកដែលមានសិទ្ធិ ហើយដែលដូចគ្នាទៅនឹងគំរូដែលតម្កល់ទុកនៅធនាគារ និងបោះត្រា (ប្រសិនបើមាន)។

៨.៥ នៅពេលធនាគារយល់ថា មូលប្បទានបត្រមិនអាចទូទាត់បាន ធនាគារអាចបង្វិលមូលប្បទានបត្រនោះទៅអ្នកកាន់វិញ (តែមិនមែនជាកាតព្វកិច្ចរបស់ធនាគារទេ) និងបញ្ជាក់ពីហេតុផលដែលមិនអាចទូទាត់បាន។ ធនាគារនឹងមិនទទួលខុសត្រូវលើផលប៉ះពាល់ដែលអាចកើតមាន ចំពោះអតិថិជន ឬភាគីទីបីណាមួយ ដោយសារការមិនទទួលយកមូលប្បទានបត្រនោះ ទោះជាមូលប្បទានបត្រនោះអាចត្រូវទទួលយកក៏ដោយ ដើម្បីឲ្យធនាគារប្រតិបត្តិក្នុងសុចរិតភាព។

៨.៦ ធនាគាររក្សាសិទ្ធិក្នុងការមិនទទួលយកមូលប្បទានបត្រណាមួយ ដើម្បីបញ្ចូលប្រាក់ទៅក្នុងគណនីទេ ប្រសិនបើឈ្មោះអ្នកទទួលមិនដូចឈ្មោះអតិថិជនក្នុងបញ្ជីដែលបានតម្កល់នៅធនាគារ។

៨.៧ ធនាគារអាចទទួលយកប្រាក់បញ្ញើជាមូលប្បទានបត្រ បានតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ការផ្ញើប្រាក់របៀបនេះនឹងចូលជាធរមាន ហើយអតិថិជននឹងទទួលបានការប្រាក់ក្រោយពេលធនាគារធ្វើការផាត់ទាត់នៅឯសភាផាត់ទាត់ជាតិរួចរាល់។ នៅពេលទទួលមូលប្បទានបត្រដាក់ប្រាក់បញ្ញើ ធនាគារនឹងចេញប័ណ្ណទទួលប្រាក់ជូនអតិថិជនដើម្បីបញ្ជាក់ និងទទួលស្គាល់ថា បានទទួលមូលប្បទានបត្រ និងដើម្បីជាមូលដ្ឋានក្នុងការបញ្ចូលទឹកប្រាក់ទៅក្នុងគណនីអតិថិជន។ ធនាគារនឹងមិនទទួលខុសត្រូវចំពោះការដាក់បញ្ញើជាមូលប្បទានបត្រណា ដែលគ្មានប័ណ្ណទទួលប្រាក់ចេញដោយធនាគារឡើយ។

៨.៨ ធនាគារដើរតួជាភ្នាក់ងារប្រមូលប្រាក់បញ្ញើជាមូលប្បទានបត្ររបស់អតិថិជន ដាក់នៅជាមួយធនាគារ។ អតិថិជនជាអ្នកទទួលហានិភ័យក្នុងការប្រមូលប្រាក់បញ្ញើនេះ។ ក្នុងករណីដែលមូលប្បទានបត្រមិនមានសាច់ប្រាក់គ្រប់គ្រាន់ ធនាគាររក្សាសិទ្ធិក្នុងការទទួលប្រាក់ពីអតិថិជន នោះវិញ ហើយធ្វើការកត់ត្រាលេខនាបញ្ច្រាសទៅលើគណនីនោះ។

## ៩ របាយការណ៍សមតុល្យគណនី និងព័ត៌មានគណនី

៩.១ គ្រប់ប្រតិបត្តិការសេដ្ឋកិច្ចដែលកើតឡើងក្នុងគណនី អតិថិជនអាចពិនិត្យ និងផ្ទៀងផ្ទាត់ប្រតិបត្តិការទាំងនោះតាមរយៈម៉ាស៊ីនអេធីអឹម សេវាអេស៊ីលីដាម៉ូបាល សេវាអេស៊ីលីដាអ៊ីនធើណែត ឬរបាយការណ៍ដែលធនាគារផ្តល់ជូន ឲ្យបានច្បាស់លាស់។ ក្នុងករណីមានភាពមិនប្រក្រតី ឬប្រសិនបើត្រួតពិនិត្យឃើញថាមានភាពខុសគ្នារវាងកំណត់ត្រារបស់ខ្លួន និងរបាយការណ៍គណនីដែលទទួលបាន ត្រូវជូនដំណឹងមកកាន់ធនាគារវិញ មិនឲ្យហួស ៦០ថ្ងៃ បន្ទាប់ពីថ្ងៃដែលប្រតិបត្តិការគណនីនោះកើតឡើង ដើម្បីឲ្យធនាគារត្រួតពិនិត្យរវាងភាពខុសគ្នានោះ និងធ្វើការកែតម្រូវឲ្យបានត្រឹមត្រូវ។ ចំពោះប្រតិបត្តិការគណនីដែលកើតឡើងដោយកំហុសអចេតនារបស់ប្រតិបត្តិករ ឬកំហុសបច្ចេកទេសប្រព័ន្ធ ធនាគារមានសិទ្ធិជាឯកច្ឆន្ទកែតម្រូវទៅតាមស្ថានភាពជាក់ស្តែង។

៩.២ រាល់លិខិតឆ្លើយឆ្លង និងលិខិតជូនដំណឹងទៅអតិថិជនស្តីពីគណនី នឹងត្រូវបញ្ជូនទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់អតិថិជន ដែលបានបំពេញនៅក្នុងបែបបទបើកគណនី ឬអាសយដ្ឋានអ៊ីម៉ែលចុងក្រោយបំផុតដែលអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារ។ ធនាគារនឹងមិនធានាថា រាល់លិខិតឆ្លើយឆ្លងគ្នា ឬលិខិតជូនដំណឹងទៅអតិថិជននោះ បានទៅដល់អតិថិជនគ្រប់ទាំងអស់ឡើយ។

៩.៣ អតិថិជនត្រូវផ្តល់សិទ្ធិជូនធនាគារក្នុងការផ្តល់ព័ត៌មានទាំងឡាយដែលទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុ និងគណនីរបស់ខ្លួន ដែលមាននៅតាមសាខាណាមួយរបស់ធនាគារ ប្រសិនបើជាការតម្រូវរបស់អាជ្ញាធរ ឬរដ្ឋអំណាចមូលដ្ឋាន ការធ្វើសវនកម្ម ករណីផ្សេងៗទៀត ដែលមានការឯកភាពពីលោក-លោកស្រី និងស្របទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

## ១០ សោហ៊ុយចំណាយ និងការទូទាត់

១០.១ ធនាគារអាចគិតកម្រៃសេវាមួយចំនួនចំពោះប្រតិបត្តិការលើគណនី ដែលសោហ៊ុយចំណាយនោះ បានបង្កើតឡើងនៅក្នុងតារាង “លក្ខខណ្ឌ និងថ្លៃសេវានៃប្រតិបត្តិការគណនី” ដើម្បីផ្តល់ជូនអតិថិជនឲ្យបានជ្រាបជាមុន ទាក់ទងនឹងព័ត៌មានគណនី និងថ្លៃសេវាផ្សេងៗ។ ចំពោះថ្លៃសេវាលើការធ្វើប្រតិបត្តិការចេញពីគណនី ត្រូវអនុលោមតាមថ្លៃសេវាដែលធនាគារបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ឬថ្លៃសេវាដែលបានព្រមព្រៀងពិសេសជាមួយធនាគារ។

១០.២ អតិថិជនត្រូវពិនិត្យលើថ្លៃសេវាដែលធនាគារដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ឬថ្លៃសេវាដែលបានព្រមព្រៀងគ្នាឲ្យបានច្បាស់លាស់ មុននឹងសម្រេចធ្វើប្រតិបត្តិការនីមួយៗ និងយល់ព្រមបង់ជាសាច់ប្រាក់ ឬឲ្យធនាគារកាត់កងទឹកប្រាក់ពីគណនីរបស់ខ្លួនដើម្បីទូទាត់កម្រៃសេវា និងការចំណាយផ្សេងៗដែលពាក់ព័ន្ធ។ ថ្លៃសេវាលើប្រតិបត្តិការដែលបានព្រមព្រៀងរួចហើយ មិនអនុញ្ញាតឲ្យកែប្រែ ឬផ្លាស់ប្តូរដោយពុំមានការយល់ព្រមពីភាគីណាមួយឡើយ។

១០.៣ អតិថិជនត្រូវបង់សោហ៊ុយចំណាយទាំងឡាយទាក់ទងទៅនឹងប្រតិបត្តិការគណនី ឬមូលប្បទានបត្រ ឬសេវាផ្សេងៗ តាមការតម្រូវរបស់ធនាគារ ហើយធនាគារនឹងកាត់យកសោហ៊ុយចំណាយ ឬថ្លៃសេវាចេញពីគណនីរបស់អតិថិជនទៅតាមស្ថានភាពជាក់ស្តែង។

១០.៤ ធនាគារមានសិទ្ធិជាឯកច្ឆន្ទក្នុងការកាត់កងប្រាក់ចេញពីគណនីរបស់អតិថិជន ដើម្បីទូទាត់បំណុល បង់ថ្លៃសោហ៊ុយចំណាយ បង់ប្រាក់ ពិន័យ និងថ្លៃសេវាផ្សេងៗទៀត ដែលអតិថិជនជំពាក់ធនាគារ ឬដើម្បីកែតម្រូវលើការទូទាត់ដែលបណ្តាលមកពីកំហុសបច្ចេកទេសណាមួយ ដោយពុំចាំបាច់ជូនដំណឹងជាមុនឡើយ ហើយធនាគារមិនទទួលខុសត្រូវលើការខាតបង់ការប្រាក់ក្នុងគណនីនោះទេ ទោះជាឯកសារតម្កល់ទុកនៅធនាគារមានការអធិប្បាយយ៉ាងណាក៏ដោយ។ ករណីគណនីមានទឹកប្រាក់មិនគ្រប់គ្រាន់ ធនាគារនឹងជូនដំណឹងអតិថិជនឲ្យមកដាក់ប្រាក់បន្ថែមនៅក្នុងគណនីឲ្យបានគ្រប់គ្រាន់។ ធនាគារនឹងគិតការប្រាក់ ២,៥% (ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ លើចំនួនទឹកប្រាក់ដែលនៅជំពាក់ លើកលែងគណនីឥណទានវិបារូបរ៍ (Overdraft)។ សិទ្ធិនេះត្រូវអនុវត្តលើគ្រប់ប្រភេទគណនី នៅគ្រប់ការិយាល័យទាំងអស់របស់ធនាគារ។

**១០.៥** ករណីមានការកែប្រែថ្លៃសេវាផ្សេងៗ ធនាគារនឹងជូនដំណឹងជាមុនរហូតដល់ ៣០ថ្ងៃ តាមរយៈមធ្យោបាយណាមួយក្នុងចំណោម ខាងក្រោម ៖

- ផ្ញើសារទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់អតិថិជន ដោយផ្ទាល់ ឬ
- ផ្សព្វផ្សាយជាសាធារណៈតាមរយៈសារព័ត៌មាន ឬ
- ជូនដំណឹងនៅការិយាល័យធនាគារ ឬ
- ជូនដំណឹងតាមរយៈគេហទំព័ររបស់ធនាគារ ឬ
- តាមមធ្យោបាយផ្សេងៗ ដែលអាចធ្វើទៅបាន។

**១០.៦** ប្រសិនបើធនាគារស្វែងរកវិធីណាមួយ ដើម្បីពង្រឹងការអនុវត្តសិទ្ធិ ឬការការពារសិទ្ធិ ឬដោះស្រាយជម្លោះណាមួយដែលទាក់ទងទៅនឹងគណនីអតិថិជន នោះអតិថិជនជាអ្នកចំណាយសងទៅធនាគារ នូវរាល់សោហ៊ុយចំណាយ និងថ្លៃសេវាផ្សេងៗទៀត ដែលអាចកើតមានឡើងជាយថាហេតុ ក្នុងនោះមានរួមបញ្ចូលទាំងការចំណាយផ្នែកច្បាប់ផង ដោយដកយកពីគណនីអតិថិជនផ្ទាល់។

**១១. កាតព្វកិច្ចសំណង**

**១១.១** អតិថិជនត្រូវយល់ព្រមសងមកធនាគារវិញដោយឥតលក្ខខណ្ឌនូវរាល់ការខូចខាត ការតវ៉ា ការទាមទារ វិធានការ បំណុល ការទទួលខុសត្រូវ ការចំណាយពាក់ព័ន្ធនឹងច្បាប់ និងរាល់ការចំណាយផ្សេងៗ ទោះជាក្រោមរូបភាពណាក៏ដោយដែលជាកំហុសទាក់ទងទៅនឹងការប្រតិបត្តិគណនីរបស់អតិថិជនគ្រប់ប្រភេទ។

**១១.២** ធនាគារនឹងមិនទទួលខុសត្រូវចំពោះរាល់ការតវ៉ា ការទាមទារ វិធានការ បណ្ដឹង ការបាត់បង់ផលប្រយោជន៍ ការចំណាយផ្សេងៗ ដែលរួមទាំងការចំណាយដែលពាក់ព័ន្ធនឹងច្បាប់ បំណុល ឬការទទួលខុសត្រូវណាមួយ ដែលជាកំហុសកើតឡើងជាយថាហេតុទាក់ទងទៅនឹង ការប្រតិបត្តិគណនីរបស់អតិថិជន ទោះជាក្រោមរូបភាពណាក៏ដោយ លើកលែងតែកំហុសបច្ចេកទេសដែលកើតឡើងដោយធនាគារ។

**១២. ផ្សេងៗ**

**១២.១** ដើម្បីជាការធានាចំពោះបំណុលរបស់ខ្លួន ធនាគារអាចរក្សាទុកនូវរាល់សម្ភារ ឬរូបិយវត្ថុ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន ឬដាក់តម្កល់ដោយអតិថិជនក្នុងឃ្លាំង ឬក្នុងកន្លែងដែលជាកម្មសិទ្ធិរបស់ធនាគារ ឬតាមរបៀបផ្សេងពីនេះ ដើម្បីរក្សាសុវត្ថិភាព។

**១២.២** ប្រសិនបើទឹកប្រាក់ដែលត្រូវបង់ទៅធនាគារ ជាទឹកប្រាក់ដែលនឹងត្រូវកាត់ទុក ឬដកទុកមួយចំនួន អតិថិជនត្រូវបង់សងទៅធនាគារនូវចំនួនទឹកប្រាក់បន្ថែមយ៉ាងណាឲ្យធនាគារទទួលបាននូវចំនួនទឹកប្រាក់សុទ្ធ ក្រោយការកាត់ទុក ឬដកទុក ស្មើនឹងចំនួនទឹកប្រាក់ដែលត្រូវបង់សងទៅធនាគារ។

**១២.៣** បំណុលអតិថិជនចំពោះធនាគារនឹងមិនប៉ះពាល់ទេ ទោះជាមានការផ្លាស់ប្តូរសមាសភាព ឬចំណុចណាមួយនៃស្ថានភាពផ្លូវច្បាប់ក៏ដោយ ហើយវានឹងភ្ជាប់កាតព្វកិច្ចដល់អ្នកស្នងមរតករបស់អតិថិជន។

**១២.៤** អតិថិជននឹងទទួលបានការប្រាក់ទៅតាមប្រភេទគណនីដែលបានកំណត់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ហើយត្រូវបានគិតបង្គរជាប្រចាំថ្ងៃ និងជាស្វ័យប្រវត្តិ ដើម្បីបញ្ចូលក្នុងគណនីអតិថិជនទៅតាមពេលវេលាកំណត់នៃប្រភេទគណនីនីមួយៗ និងត្រូវកាត់ពន្ធទៅតាមអត្រាដែលបានកំណត់ដោយនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយកាត់ចេញពីគណនីអតិថិជនដោយស្វ័យប្រវត្តិ។

**១២.៥** គណនីគ្រប់ប្រភេទដែលគ្មានប្រតិបត្តិការ ដក-ដាក់ប្រាក់ ផ្ទេរប្រាក់/ទូទាត់ចេញ-ចូលគណនីនៅតាមបញ្ជរ តាមប្រព័ន្ធធនាគារអេឡិចត្រូនិក ឬឌីជីថល និងកម្រៃសេវាផ្សេងៗដែលអតិថិជនកាត់ចេញពីគណនី និងប្រតិបត្តិការដែលធ្វើឡើងដោយធនាគារផ្ទាល់ ដូចជា ការគិតការប្រាក់ ឬការគិតថ្លៃសេវាកម្មផ្សេងៗ អស់រយៈពេលលើសពី ១២ខែ ឡើងទៅ ត្រូវចាត់ទុកថាជាគណនីនៅស្ងៀមឬគ្មានសកម្មភាព និងត្រូវគិតកម្រៃសេវា ទៅតាមការកំណត់របស់ធនាគារ ដោយកាត់ចេញពីគណនីអតិថិជនដោយផ្ទាល់។

**១២.៦** ករណីលក្ខខណ្ឌណាមួយដែលបានចែងខាងលើនេះ មិនស្របនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ប៉ុន្តែពុំធ្វើឲ្យប៉ះពាល់ដល់សុពលភាពអនុវត្តលក្ខខណ្ឌដទៃទៀតឡើយ។

**១២.៧** លោក-លោកស្រីអាចយល់ព្រមតាមលក្ខខណ្ឌកំណែទម្រង់ចុងក្រោយដែលមានរក្សាទុកនៅក្នុងគេហទំព័រផ្លូវការរបស់អេស៊ីលីដា តាមរយៈការធីក (✓) យល់ព្រមនៅក្នុងទម្រង់បើកគណនី ហើយរក្សាទុកក្នុងឯកសារបើកគណនីអតិថិជន ឬអាចទទួលយកតាមមធ្យោបាយអេឡិចត្រូនិកផ្សេងៗ ដែលធនាគារអាចធ្វើទៅបាន ដើម្បីបញ្ជាក់ក្នុងការប្រើប្រាស់គណនីជាមួយធនាគារបានត្រឹមត្រូវ។ ក្នុងករណីដែលអត្ថបទជាភាសាខ្មែរមានអត្ថន័យខុសគ្នានឹងអត្ថបទជាភាសាអង់គ្លេស នោះអត្ថបទជាភាសាខ្មែរត្រូវបានទទួលយកជាផ្លូវការ។

ខ្ញុំ/យើងខ្ញុំ បានអាន យល់ និងព្រមព្រៀងគ្រប់ខចែង ដែលមានរៀបរាប់នៅក្នុងលក្ខខណ្ឌទូទៅខាងលើ។